# ប្រវត្តិសង្ខេបនៃសន្និសីទរវាងពុទ្ធបរិស័ទ និងគ្រីស្តបរិស័ទអន្តរជាតិ

- សន្និសីទលើកទី១ : «ព្រះពុទ្ធសាសនា និងគ្រីស្តសាសនា : ភាពប្រសព្វគ្នា និងភាពខុសប្លែកគ្នា» ថ្ងៃទី៣១ ខែកក្កដា ដល់ទី៤ ខែសីហា ឆ្នាំ១៩៩៥ នៅអារាមព្រះពុទ្ធសាសនាមហាយាន ហ្វូគួងសាន ទីក្រុង កៅស៊្យុង ប្រទេសតៃវ៉ាន់ សាធារណរដ្ឋចិន។ សមាជិកចូលរួមមានអ្នកខាងព្រះពុទ្ធសាសនា១០រូប និងអ្នកខាងគ្រីស្តសាសនា១០រូប មកពីប្រទេសជប៉ុន តៃវ៉ាន់ ស្រីលង្កា ថៃ សហរដ្ឋអាមេរិច និងអ៊ីតាលី។
- សន្និសីទលើកទី២ : «ព្រះបន្ទូល និងភាពស្ងៀមស្ងាត់ក្នុងប្រពៃណីព្រះពុទ្ធសាសនា និងគ្រីស្តសាសនា» ថ្ងៃទី ៨ ដល់១៣ ខែកក្កដា ឆ្នាំ១៩៩៨ នៅអារាមបេណេឌីកទីន អាសៀវ៉ាន់ណាំ ទីក្រុងបាំងហ្គាឡូ ប្រទេសឥណ្ឌា។ សមាជិកចូលរួមមានចំនួន១៨នាក់មកពីប្រទេសផ្សេងគ្នា មានពុទ្ធបរិស័ទ៧រូប និងគ្រីស្តបរិស័ទ១១រូប។
- សន្និសីទលើកទី៣ : «សហគមន៍ព្រះសង្ឃក្នុងព្រះពុទ្ធសាសនា និងព្រះសហគមន៍ក្នុងគ្រីស្តសាសនា» ថ្ងៃទី ២៩ ខែកញ្ញា ដល់ទី៣ ខែតុលា ឆ្នាំ២០០០ នៅទីស្នាក់ការកណ្តាលនៃសមាគមពុទ្ធបរិស័ទ រីស្សូ កូសេកៃ ទីក្រុងតូក្យូ ប្រទេសជប៉ុន។ សមាជិកចូលរួមមកពី ប្រទេសសិង្ហបុរី ហុងកុង ម៉ាកាវ ជប៉ុន ឥណ្ឌា មីយ៉ាន់ម៉ា កូរ៉េខាងត្បូង ស្រីលង្កា តៃវ៉ាន់ ថៃ អ៊ីតាលី និងសហរដ្ឋអាមេរិក។
- សន្និសីទលើកទី៤ : «សន្តិភាពក្នុងចិត្ត និងក្នុងចំណោមប្រជាជន» ថ្ងៃទី៦ ខែឧសភា ឆ្នាំ២០១៣ នៅសាកលវិទ្យាល័យសម្តេចប៉ាបអ៊ូបាននៀណា ទីក្រុងរ៉ូម ប្រទេសអ៊ីតាលី។ សមាជិកចូលរួមមក ពីប្រទេស អ៊ីតាលី ជប៉ុន សាធារណរដ្ឋចិន (តៃវ៉ាន់) វៀតណាម កូរ៉េខាងត្បូង ថៃ មីយ៉ាន់ម៉ា ស្រីលង្កា និងឥណ្ឌា។
- សន្និសីទលើកទី៥ : «ពុទ្ធបរិស័ទ និងគ្រីស្តបរិស័ទរួមគ្នាលើកស្ទួយភាតរភាព» ថ្ងៃទី១២ ដល់១៣ ខែកុម្ភៈ ឆ្នាំ ២០១៥ នៅបូហ្គាយ៉ា ប្រទេសឥណ្ឌា។ សមាជិកចូលរួមមានទាំងពីរសាសនា មកពីប្រទេសសេរីឡាំងកា ថៃ កូរ៉េខាងត្បូង ជប៉ុន មីយ៉ាន់ម៉ា ម៉ុងហ្គោលី តៃវ៉ាន់ និងឥណ្ឌា។
- សន្និសីទលើកទី៦ : «ពុទ្ធបរិស័ទ និងគ្រីស្តបរិស័ទធ្វើដំណើររួមគ្នាលើមាគ៌ាអហិង្សា» ថ្ងៃទី១៣ ដល់១៥ ខែវិច្ឆិកា ឆ្នាំ២០១៧ នៅអារាមព្រះពុទ្ធសាសនា លីងជីអ៊្វូ។ សមាជិកចូលរួមមកពី១៨ប្រទេស រួមមានតៃវ៉ាន់ ជាម្ចាស់ផ្ទះ បុរីវ៉ាទីកង់ (ក្រសួងកិច្ចសន្ទនាអន្តរសាសនា) អ៊ីតាលី ជប៉ុន កូរ៉េខាងត្បូង ថៃ មីយ៉ាន់ម៉ា សេរីឡាំងកា ឥណ្ឌា វៀតណាម សិង្ហបុរី សហរដ្ឋអាមេរិក អាល្លឺម៉ង់ ចក្រភពអង់គ្លេស កម្ពុជា បារាំង និងហុងកុង។
- សន្និសីទលើកទី៧ : «កិច្ចសន្ទនាដោយសេចក្តីករុណា និងសេចក្តីស្រឡាញ់ ដើម្បីព្យាបាលរបួសមនុស្សលោក និងភពផែនដី» ថ្ងៃទី១៣ ដល់១៦ ខែវិច្ឆិកា ឆ្នាំ២០២៣ នៅទីក្រុងបាងកក ប្រទេសថៃ។ សមាជិកចូលរួមមកពីប្រទេសកម្ពុជា ហុងកុង ឥណ្ឌា ជប៉ុន ម៉ាឡេស៊ី ម៉ុងហ្គោលី មីយ៉ាន់ម៉ា សិង្ហបុរី សេរីឡាំងកា កូរ៉េខាងត្បូង ថៃ តៃវ៉ាន់ ចក្រភពអង់គ្លេស និងសន្តអាសនៈ។